**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការក្រុងព្រះសីហនុ**
សំណុំរឿងព្រហ្មទណ្ឌ
លេខ ០១ ចុះថ្ងៃទី ០៥
ខែ មករា ឆ្នាំ ២០០៤

សាលក្រម
លេខ ២៨ ចុះថ្ងៃទី ៣០
ខែ មេសា ឆ្នាំ ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅនេះ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញាអមតុលាការក្រុងព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងព្រះសីហនុ

សាលក្រមនេះចូលជាស្ថាពរនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៤
ក្រុងព្រះសីហនុ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
ក្រឡាបញ្ជី [redacted]

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ០១ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះខាងក្រោមនេះ :

១-ឈ្មោះ **ឌ ណារ** ហៅ **ណាព** ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិរាម ឃុំរាម ស្រុកព្រៃនុប ក្រុងព្រះសីហនុ ទីលំនៅសព្វថ្ងៃ ភូមិ ៤ សង្កាត់ ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ី នៅផ្ទះ ឪពុកឈ្មោះ **ឌ ភ** (ស) ម្តាយឈ្មោះ **លសម** (រ) នៅលីវ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ ០៣ដង ។ ចាប់ខ្លួនថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ។

ត្រូវចោទពីបទ "ចោរកម្ម" ប្រព្រឹត្តនៅភូមិ ២ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោស តាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ទ បញ** ហៅ **ទ** ភេទប្រុស អាយុ ៤៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី ៨ មណ្ឌល ២ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ី លក់ម្នាងសិលាជាដើមបណ្តឹង ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១២៦ ដ.ស.ព 0៤ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៤ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៣៥០ ត.ដ 0៤ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

## **ដំណើររឿងមានដូចតទៅ :**

កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ វេលាម៉ោងប្រហែល ២.០០ទៀបភ្លឺ ឈ្មោះ **ឧ ណរ** ហៅ **ឧ ណាព** ភេទប្រុស អាយុ ២២ឆ្នាំ បានឡើងលើដំបូលផ្ទះរបស់លោក **ទ មញ** ស្ថិតនៅក្រុមទី ៨ ភូមិ ២ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ក្នុងបំណងចូលទៅក្នុងផ្ទះធ្វើសកម្មភាពលួចទ្រព្យសម្បត្តិក្នុងផ្ទះនោះ តែត្រូវអ្នកជិតខាង និង ម្ចាស់ផ្ទះដឹងទាន់ ក៏បានចាប់ខ្លួនជនល្មើសបានទាន់ពេលវេលា ដោយមិនបណ្តោយអោយបាត់បង់ទ្រព្យសម្បត្តិអ្វីឡើយ ក្រោយពេលចាប់ខ្លួនជនល្មើសបានម្ចាស់ផ្ទះបានប្រគល់ជូនសមត្ថកិច្ចចាត់ការតាមច្បាប់ ។

## **នាពេលសវនាការ**

-ឈ្មោះ **ឧ ណរ** ហៅ **ណាព** ជាជនជាប់ចោទបានឆ្លើយថា នៅថ្ងៃមិនចាំ ខែ មករា ឆ្នាំ ២០០៤ ខ្លួនបានទិញថ្នាំញៀនជក់តាំងពីព្រឹករហូតដល់ល្ងាច ធ្វើអោយខ្លួនវិលវល់ ឃើញមនុស្សចង់តែរត់ ។ លុះដល់ម៉ោងប្រហែល ១០:០០យប់ ខ្លួនបានទិញថ្នាំញៀនម្តងទៀតពីឪស្តូថេក "អង្គរ" គឺទិញបានពីឈ្មោះ **ឃ** ។ ក្រោយពេលខ្លួនជក់ថ្នាំញៀនអស់មានក្រុមបងធំដែលខ្លួនពុំស្គាល់មួយក្រុម ថាចង់អាករខ្លួន ខ្លួនភ័យពេកក៏រត់ឡើងលើដំបូលផ្ទះគេ ដោយបានយកដុំឥដ្ឋការ៉ូ ០៦ដុំ សំរាប់គប់ទៅលើពួកវា ។ ពេលខ្លួនឃើញស្រមោលមនុស្សស្ងង់ៗ ក៏គប់ដុំឥដ្ឋនោះទៅ ។ ប្រហែលជា ០១ម៉ោងក្រោយមកម្ចាស់ផ្ទះគេបានឡើងមកលើ ឃើញមានកាន់កាំបិតប៉ុងតោ ០១ផង ខ្លួនក៏សុំអោយគាត់ទុកកាំបិត ហើយខ្លួននឹងអោយគាត់ចាប់តាមសំរូល ។ ពេលគាត់ចាប់ខ្លួន ហើយអោយខ្លួនចុះមកដីតាមសំរូលខ្លួនខ្លាចគាត់ធ្វើបាបខ្លួន ខ្លួនក៏លោតទៅលើដំបូលផ្ទះគេមួយទៀត ហើយធ្លាយដំបូលមកដីហើយត្រូវគេចាប់ខ្លួនបានតែម្តងទៅ ។ ក្នុងរឿងនេះខ្លួនសុំបញ្ជាក់ជូនតុលាការថា ខ្លួនគ្មានបំណងចូលលួចអ្វីឡើយ ហើយសុំអោយតុលាការជួយអោយខ្លួនរួចផុតពីការញៀនថ្នាំ និងជួយលើកលែងទោសដល់ខ្លួនផងចុះ ។

-ឈ្មោះ **ទ មញ** ជាដើមបណ្តឹង បានឆ្លើយថា កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ ប្រហែលជាម៉ោង ២:០០ អ្នកជិតខាងជាប់ផ្ទះខ្លួន បានទូរស័ព្ទមកប្រាប់កូនស្រីខ្លួនឈ្មោះ **ទ ភនភ** ថា ដូចជាមានមនុស្សនៅលើដំបូលផ្ទះ ពេលកូនស្រីខ្លួនប្រាប់ ខ្លួនក៏ឡើងទៅមើលឃើញមនុស្ស ខ្លួនក៏ចុះមកយកប៉ុងតោ ហើយឡើងទៅលើវិញឃើញជនល្មើសទាញបំពង់ទឹបមកកាន់នៅដៃជាប់ ខ្លួនក៏ស្រែកគំរាមអោយទម្លាក់បំពង់ទឹបចុះ រួចខ្លួនស្ទុះទៅតៀកវាជាប់វាបាននិយាយអង្វរខ្លួន កុំអោយធ្វើបាបវា ។ ខ្លួនបានលែងវាអោយចុះមកដី ពេលនោះជនល្មើសក៏រត់តាមថ្មីមដំបូលផ្ទះ ហើយទម្លាក់ខ្លួនលើដំបូលស័ង្កសីដល់ធ្លុះស័ង្កសី ធ្លាក់ចុះមកដីក្នុងរបងផ្ទះខ្លួន រួចវាប្រុងលោតមកថ្នល់ តែត្រូវក្រុមកម្មករជាងដែកខ្លួនចាប់បានតែម្តង ។ ក្នុងរឿងនេះខ្លួនមិនទាមទារសំណងជម្ងឺចិត្តអ្វីឡើយ និង សុំអោយតុលាការធ្វើតាមច្បាប់ចុះ ។

-ឈ្មោះ **ឧ សរ** ជាសាក្សីដើមបណ្តឹងបានឆ្លើយថា ខ្លួនមានទីលំនៅជិតផ្ទះជនរងគ្រោះ គឺរំលងតែមួយផ្លូវលំប៉ុណ្ណោះ ។ នៅថ្ងៃកើតហេតុ ទាថ្ងៃខែមិនចាំ ក្នុងឆ្នាំ ២០០៤ វេលាម៉ោងប្រហែលជា ០២ និង ៣០នាទីទៀបភ្លឺខ្លួនកំពុងសំរាកក៏បានឮកូនស្រីរបស់ជនរងគ្រោះស្រែកថា មានចោរខ្លួនក៏ក្រោកដើរទៅផ្ទះកើតហេតុនោះ ក៏ឮលោក **មញ** ស្រែកអោយជួយចាប់ចោរផង ស្រាប់តែចោរនោះក៏លោតពីលើដំបូលផ្ទះកំពស់ប្រហែល ០៦ម៉ែត្រ ហើយក៏ធ្លាក់លើសំយ៉ាបស័ង្កសី ហើយធ្លុះស័ង្កសីធ្លាក់ដល់ក្រោមតែម្តង ។ ពេលខ្លួនកំពុងយាមនៅក្រៅរបងចាំចាប់ជនល្មើសនោះ វាក៏ឡើងលើរបងចេញមកខាងក្រៅផ្ទះខ្លួន និង អ្នកជិតខាងផ្សេងៗទៀត ក៏ចាប់វាបានយកមកប្រគល់ជូនសមត្ថកិច្ចតែម្តងទៅ ។ ឯរឿងអ្វីផ្សេងទៀតខ្លួនពុំបានដឹងទៀតឡើយ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ឧ ណរ** ហៅ **ណាព**

ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិ ២ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហេតុដូច្នេះសុំឱ្យចៅក្រមវិនិច្ឆ័យទៅតាមច្បាប់ដោយអនុគ្រោះ ។

-ជនជាប់ចោទបានឆ្លើយសំដីចុងក្រោយបង្អស់ថា ខ្លួនសុំអោយតុលាការជួយបន្ធូរបន្ថយទោសអោយខ្លួនផង ហើយខ្លួនឈប់ប្រព្រឹត្តអំពើយ៉ាងដូច្នេះតទៅទៀតហើយ ខ្លួននឹងខិតខំកែប្រែលត់ដំខ្លួនអោយបានល្អនៅក្នុងសង្គម ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

## <u>តុលាការខេត្តព្រះសីហនុ</u>

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>យល់ឃើញថា</u>

-ឈ្មោះ **ឧ ណរ** ហៅ **ណាត** កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ វេលាម៉ោងប្រហែល ២:០០ បានឡើងលើដំបូលផ្ទះរបស់ឈ្មោះ **ខ មញ** បំរុងធ្វើសកម្មភាពលួចប្រាកដមែន តែត្រូវម្ចាស់ផ្ទះដឹងទាន់ ហើយចាប់ឈ្មោះនេះអោយចុះមកក្រោមវិញ តែឈ្មោះនេះបែរជារកគ្រប់មធ្យោបាយគេចខ្លួនទៅវិញ នេះបញ្ជាក់ថា ឈ្មោះនេះភ័យខ្លាចនឹងទង្វើរបស់ខ្លួន ។

-តាមចម្លើយបញ្ជាក់របស់សាក្សីបានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនពិតជាបានឃើញជនល្មើសនៅលើដំបូលផ្ទះរបស់លោក **ខ មញ** ហើយពួកគេក៏បានជួយព័ទ្ធចាប់ជនល្មើសថែមទៀត ចម្លើយសាក្សីមានមូលដ្ឋានគួរអោយតុលាការជឿបាន ។

-តាមចម្លើយរបស់លោក **ខ មញ** បានបញ្ជាក់ដែលថា ពេលខ្លួនចាប់បានជនល្មើស ដោយជនល្មើសអង្វរពេក ខ្លួនក៏អោយវាដើរតាមធម្មតា តែវាមិនដើរតាមធម្មតាទេ គឺវារត់ហើយលោត តែលោតមិនផុតពីក្រៅរបង គឺធ្លាក់ចុះក្នុងបរិវេណផ្ទះរបស់ខ្លួនដដែល ដោយលោតត្រូវដំបូលស័ង្កសី ហើយធ្លាក់ចុះមកក្រោម ហើយរត់ទៀត ក៏ត្រូវបានកម្មករព័ទ្ធចាប់តែម្តង ក្នុងបញ្ហានេះមានការខូចខាតស័ង្កសីតិចតួច តែសុំអោយជនល្មើសខិតខំកសាងខ្លួន ខ្លួនមិនទាមទារសំណងអ្វីទេ ។

-តាមចម្លើយជនល្មើសបានបញ្ជាក់ថា ខ្លួនគ្មានបំណងលួច ឬប្លន់ទ្រព្យសម្បត្តិអ្នកដទៃទេ គឺខ្លួនភ័យដោយសារក្រុមបងធំមានបំណងចង់សម្លាប់ និងអារកខ្លួន ខ្លួនក៏រត់ឡើងលើដំបូលផ្ទះគេនោះទៅ តែការឡើងលើដំបូលផ្ទះនេះគឺជនល្មើសឡើងនៅពេលយប់ពុំមានការអនុញ្ញាតពីម្ចាស់ផ្ទះ នោះគឺជាការរំលោភសិទ្ធិលើលំនៅដ្ឋានអ្នកដទៃ តែទោះបីឈ្មោះនេះបានឆ្លើយថាគ្មានបំណងលួចក៏ដោយ បើពិនិត្យសាវតាជាតិរបស់ជនល្មើស ឃើញថាធ្លាប់ជាប់គុក ០៣លើកមកហើយ សុទ្ធតែបទល្មើសចោរកម្មមួយលើក១ ក៏ត្រូវបានតុលាការផ្តន្ទាទោសរួចហើយដែរ តែលើកនេះការប៉ុនប៉ងលួចមិនបានសំរេចឡើយ ទោះបីមិនបានសំរេចក៏ដោយ ក៏ក្នុងច្បាប់បានចែងពីការប៉ុនប៉ងនេះដែរ ដូច្នេះឈ្មោះនេះក៏ត្រូវតែផ្តន្ទាទោសតាមច្បាប់ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឱ ណារ ហៅ ណាព ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ ពីបទ ចោរកម្ម ប្រព្រឹត្តនៅភូមិ២ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ**

**សំរេច :**

១-ផ្តន្ទាទោសឈ្មោះ ឱ ណារ ហៅ ព ភេទប្រុស អាយុ ២០ឆ្នាំ ជាតិ ខ្មែរ ដាក់ពន្ធនាគារកំណត់ ០៧ខែ ( ប្រាំពីរខែ ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិ ២ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ ដើមបណ្តឹង បើកផ្លូវឧទ្ធរណ៍ក្នុងអំឡុងច្បាប់ ។

**ក្រឡាបញ្ជី** **ចៅក្រមជំនុំជំរះ**

[redacted] [redacted]